# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីធម៌របស់ព្រះពុទ្ធសាសនាពីរប្រការ
## គឺសតិ និងសម្បជញ្ញៈ

**web site ៖ hoksavann.org**

ថ្ងៃទី២៦ វិច្ឆិកា ២០០៥

សតិនិងសម្បជញ្ញៈជាពីរប្រការ មានឧបការៈច្រើនដល់អ្នកអនុវត្តគ្រប់កិច្ចការ ទាំងផ្លូវលោកនិងផ្លូវធម៌ ។ <សតិ> ប្រែថា សេចក្ដីរលឹក ។ <សម្បជញ្ញៈ> ប្រែថា សេចក្ដីដឹងខ្លួនពេលកំពុងអនុវត្តកិច្ចការ ។ តាមផ្លូវធម៌ សតិគឺជាការរលឹកនូវអំពើគ្រប់យ៉ាងដែលបានធ្វើកន្លងមក ដែលជាគុណធម៌ជំរុញចិត្ត ឲ្យប្រព្រឹត្តល្អតទៅទៀត បើអំពើដែលធ្វើកន្លងមក ជាអំពើល្អ ហើយនិងលះបង់នូវអំពើអាក្រក់មិនធ្វើតទៅទៀត ។ សម្បជញ្ញៈដឹងខ្លួនពេលកំពុងប្រព្រឹត្តធ្វើ, ការដឹងនេះជាធាតុសំខាន់ណាស់ ក្នុងការអប់រំចិត្តឲ្យបានល្អ ។ ធម៌ទាំងពីរនេះជាធម៌គូនឹងគ្នា ត្រូវតែបណ្ដុះឲ្យមានទាំងពីរ ទើបសំរេចប្រយោជន៍បាន ។ ធម៌ទាំងពីរនេះបើអនុវត្តកិច្ចការផ្លូវលោកក្នុងជីវភាពប្រចាំថ្ងៃមានប្រយោជន៍ណាស់ ។ សតិការរលឹកកិច្ចការដែលធ្វើកន្លងហើយ តើចំរើនលូតលាស់ឬយ៉ាងណា ត្រូវរៀបចំផែនការជាថ្មី បើពុំបានលូតលាស់ទេ គឺទុកអតីតកាលជាមេរៀន សំរាប់រៀបចំបច្ចុប្បន្ន ដើម្បីអនាគតរុងរឿង ទាំងផែនការគ្រួសារ ទាំងផែនការប្រទេស ។ សម្បជញ្ញៈ ការដឹងខ្លួនថា ខ្លួនកំពុងធ្វើអ្វីដោយពិចារណាថា តើការងារនោះមានប្រយោជន៍ឬគ្មានប្រយោជន៍ទេ ជាការទុច្ចរិតឬសុចរិតជាដើម ។ បើអ្នកបើករថយន្តវិញ បើគ្មានសម្បជញ្ញៈនិងការភ្លេចស្មារតី រថយន្តអាចគ្រោះថ្នាក់ ដោយការបើកបរខុសច្បាប់ មានទៅបុកគេជាដើម ។ ការខ្វះសតិនិងសម្មជញ្ញៈកិច្ចការច្រើនភ្លាត់ខុសហើយសោកស្ដាយជាក្រោយ។ ដូចរឿងត្រីរ៉ស់ក៏រួចទន្សាយក៏រួច ដោយដំណាលថា តាចាស់ម្នាក់បានលូកចាប់ត្រី ដែលខ្លួនប្រោះទុកក្នុងទ្រុងដោយគ្មានការប្រុងប្រយ័ត្ន ត្រីរ៉ស់រើខ្លួនរួចលោតទៅក្នុងទឹកបាត់ទៅ គាត់រត់ទៅយកអង្រុត ដែលគាត់ក្រុងទន្សាយមករុតត្រី ទន្សាយក៏បោលទៅ

បាត់ទៅទៀត ឯត្រីពុំអាចរុតបានឡើយ នេះការងារខ្វះសតិនិងសម្បជញ្ញៈថាទន្សាយនៅក្នុងអង្រុត ។

ក្នុងសតិបដ្ឋានសូត្រមាននិយាយថា សតិបដ្ឋានប្រែថាការដំកល់ស្មារតីពិចារណា, ពិចារណាវេទនា គឺការទទួលអារម្មណ៍ជាសុខជាទុក្ខ ប្រព្រឹត្តទៅក្នុងកាយនិងចិត្ត ពិចារណាផ្លូវចិត្ត ពិចារណានូវធម្មៈ គឺអារម្មណ៍ដែលកើតក្នុងចិត្ត ថាគ្រាន់តែជាធាតុ ពុំមែនជាសត្វជាបុគ្គលមានសភាពសោះសូន្យទទេ ។ គឺការកំណត់ពិចារណានូវភាពប្រាកដឡើងនៃអាការៈទាំងនោះ ។ គេពុំអាចពិចារណាជាតួបរមត្ថបែបនេះបានឡើយ លុះត្រាតែព្រះអរិយបុគ្គលមានសោតាបន្នបុគ្គលជាដើម ដែលមានញាណទស្សនៈ ទើបដឹងភាពពិតនេះបាន ។៚

❑ ❑

❑